FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute



# សត្វកណ្ដុរពេលទុកដាក់ផលិតផល



សត្វកណ្ដុរបីប្រភេទសំខាន់ៗ ជាងគេនៅក្នុងការទុកដាក់ មានដូចជា:

-កណ្ដុរប្រែងខ្មៅ ឬកណ្ដុរប្រែងនៅតាមផ្ទះពិសេសតាមលូទឹក

-កណ្ដុរប្រែងកវែង ឬកណ្ដុរប្រែងធម្មតា

-កណ្ដុរតូចៗឬកណ្ដុរបង្កង់នៅតាមផ្ទះ

គេប៉ាន់ប្រមាណថា កណ្ដុរប្រែងបំផ្លាញផលិតផលគ្រាប់ធញ្ញជាតិនៅលើពិភពលោកអស់ជាង ១% និងពី ៣-៥ %នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ពួកវាអាចចម្លងជំងឺប្រហែលជា ៥០ ប្រភេទទៅលើមនុស្សរួមមាន ៖ ជំងឺគ្រុនពោះវៀន ជំងឺកមរមាស់ និងគ្រុនសន្ទំស្រាល។ ពួកវាក៏ជាភ្នាក់ងារចម្លងជំងឺដ៏ធំមួយដែរ ដែលជះឥទ្ធិពលអាក្រក់ទៅលើពពួកសត្វស្រុក ។

កណ្ដុរប្រែងស៊ីអាហារប្រហែលជា ២៥ក្រាម ហើយកណ្ដុរតូចៗប្រហែលជា ៣-៤ក្រាមក្នុងមួយថ្ងៃ ។ ពួកវាធ្វើឱ្យប្រឡាក់ផលិតផលដែលរក្សាទុកជាច្រើនដោយសារទឹកនោម លាមក រោម និងភ្នាក់ងារបង្ករោគផ្សេងៗទៀត ។ គំនរដែលពួកវារស់នៅ ជាញឹកញាប់គេប្រកាសថាវាមិនសមរម្យសម្រាប់មនុស្សប្រើប្រាស់នោះទេ ។

វាបំផ្លាញ តង់កៅស៊ូ ការ៉ុង ឈើទម្រ ប្រដាប់បាញ់ទឹក រួមទាំងឃ្លាំងផងដែរ (ខ្សែពួរ ឬខ្សែភ្លើងទ្វារ....)។ ជាញឹកញាប់បណ្ដាលឱ្យមានការខូចខាតដូចខាងក្រោមនេះ ៖

• ផលិតផលធ្លាយចេញពីការ៉ុង ឬសម្ភារៈស្តុកទុក

• គំនរបាវដួលរលំ

• ធ្វើឱ្យចេញផ្កាភ្លើង ឬភ្លើង ពីកន្លែងប៉ះគ្នានៃខ្សែភ្លើង

• ស៊ីឡូ ឬឃ្លាំងស្តុកអាចស្រុតចុះ ឬដួលរលំ ដែលជាលទ្ធផលនៃការទំលាយចោល

• បំផ្លាញប្រព័ន្ធបង្ហូរទឹកជុំវិញឃ្លាំង

**សញ្ញាណាមួយចំនួនដែលបង្ហាញពីការរុករានរបស់ពពួកសត្វកណ្ដុរ ៖**

• **សត្វរស់ :** ពពួកសត្វកកេរគឺសកម្មណាស់នៅពេលយប់ ប្រសិនបើគេឃើញវានៅពេលថ្ងៃ វាជាសញ្ញាមួយនៃដំណាក់កាលរុករានខ្លាំងក្លាទៅហើយ ។

• **លាមក :** រូបរាង ទំហំ និងសភាពលាមកអាចឱ្យដឹងពីប្រភេទនៃសត្វកណ្ដុរ និងកម្រិតនៃការរុករានរបស់វា ។ លាមកស្រស់គឺទន់ហើយភ្លឺ ដែល ពី ២-៣ថ្ងៃក្រោយមកប្រែក្លាយទៅជាស្រួយហើយខ្មៅស្រអាប់ ឬប្រផេះ។

• **ការឆ្លងកាត់ និងស្នាម :** ស្នាមនៅតាមជើងជញ្ជាំង របង ឬក៏នៅលើកម្រាលឥដ្ឋ ។ ពពួកកណ្ដុរប្រែងវាមិនរត់ឆ្លងកាត់ទីកន្លែងស្រឡះទេ ។

• **ស្នាមជើង និងកន្ទុយ :** រកមើលស្នាមជើងនិងកន្ទុយនៅលើធូលីដី ។ ម្សៅដែលឃើញរាយប៉ាយជាច្រើនកន្លែងនៅលើកម្រាលអាចជាសញ្ញានៃដានកណ្ដុរ ។

**ពិនិត្យទៅលើការបំផ្លាញ :**

• កណ្ដុរប្រែងវាបន្សល់ទុកផ្នែកយ៉ាងធំរបស់ដំណាំដោយពួកវាស៊ីច្បិចតិចៗ (ដូចជា ឃើញមានស្នាមកកេរ) តែបើពពួកកណ្ដុរតូចៗ វិញ ឃើញមានសំណល់សល់តិចតួច ។

• បារដែលវាបំផ្លាញឃើញមានគ្រាប់ដំណាំកំពប់ឬជ្រុះខ្ចាត់ខ្ចាយ

• មានកូនគំនរគ្រាប់តូចនៅខាងក្រោមគំនរបារគ្រាប់

• បំផ្លាញសម្ភារៈនិងឧបករណ៍ប្រើប្រាស់

**ធ្វើរន្ធ ឬសម្បុក :**

នៅក្នុងឃ្លាំង ដូចជា តាមជ្រុង និងដំបូល ឯខាងក្រៅឃ្លាំង ដូចជា ក្នុងរន្ធ តំបន់ដែលមានដំណាំដុះពេសពេញ ឬក្នុងរណ្ដៅជិតៗឃ្លាំងជាដើម ។ ទំហំរន្ធកណ្ដុរប្រែងគឺ ៦-៨សង្ទីម៉ែត្រ ចំណែកឯកណ្ដុរតូចៗគឺ ២ សង្ទីម៉ែត្រ ។

ទឹកនោម ស្នាមទឹកនោមគឺទទួលពន្លឺនៅក្នុងពន្លឺអុលត្រាវីយូឡេ ។ នៅទីកន្លែងសមស្របយើងអាចប្រើអំពូលអុលត្រាវីយូឡេ ដើម្បីរកមើលស្នាមទឹកនោម ។